**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសមន្ត្រីស្ម័គ្រចិត្តចូលបម្រើការងារនៅទីភ្នាក់ងារជាតិមុខរបរ និងការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្រសួងត្រូវការជ្រើសរើសមន្ត្រីស្ម័គ្រចិត្តចំនួន **៤០រូប** (វេនព្រឹក ចំនួន ២០រូប និងវេនរសៀល ចំនួន ២០រូប) ឱ្យមកបម្រើការងារនៅទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមលក្ខខណ្ឌដូចខាងក្រោម៖

- **វេនការងារ៖**
  - វេនព្រឹកចាប់ពីម៉ោង ៧:៣០ ព្រឹក ដល់ ១១:៣០ ថ្ងៃត្រង់
  - វេនរសៀលចាប់ពីម៉ោង ១:៣០ រសៀល ដល់ ៥:៣០ ល្ងាច
- **កិច្ចការអនុវត្តន៍៖**

  ១-ទទួលស្វាគមន៍ និងជួយសម្របសម្រួលដំណើការទទួលសេវាការងារ ដល់អ្នកប្រើប្រាស់សេវា

  ២-ពិនិត្យផ្ទៀងផ្ទាត់ឯកសារចាំបាច់នានារបស់អ្នកប្រើប្រាស់តាមប្រភេទសេវានីមួយៗ

  ៣-រៀបចំនិងសម្របសម្រួលក្នុងការផ្តល់ប្រឹក្សាយោបល់ អាជីព ការងារ និងសម្ភាសន៍ការងារ

  ៤-ផ្តល់ព័ត៌មានអំពីឱកាសការងារដល់អ្នកស្វែងរកការងារ និងការជ្រើសរើសបុគ្គលិកដល់និយោជក

  ៥-ជួយដល់កិច្ចការចុះឈ្មោះ ផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារទៅកាន់និយោជក

  ៦-ប្រមូល និងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រ

  ៧-ផ្តល់ព័ត៌មានអំពីសេវាការងារតាមរយៈបណ្តាញទូរស័ព្ទ

  ៨-ចូលរួមរៀបចំកម្មវិធីសិក្ខាសាលា កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ពិព័រណ៍ការងារ និងព្រឹត្តការណ៍ការងារផ្សេងទៀត

  ៩-ជួយសម្របសម្រួលសកម្មភាពផ្សព្វផ្សាយគ្រប់ប្រភេទពាក់ព័ន្ធឱកាសការងារ និងការជ្រើសរើសបុគ្គលិក

  ១០-ជួយសរសេរអត្ថបទព័ត៌មានខ្លីៗ និងការផ្សព្វផ្សាយតាមបណ្តាញសង្គម

  ១១-ទទួលអនុវត្តសកម្មភាពផ្សេងទៀតតាមការចាត់តាំងជាក់ស្តែង
- **លក្ខខណ្ឌនៃការជ្រើសរើស៖**

  ១-មានសញ្ជាតិខ្មែរ និងអាយុចាប់ពី១៨-៣៥ឆ្នាំ

  ២-ចេះប្រើប្រាស់កុំព្យូទ័រ (Microsoft Office)

  ៣-ចំណេះដឹងភាសាអង់គ្លេសល្អ ឬភាសាបរទេសផ្សេងទៀត

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៤-អាចធ្វើការងារជាក្រុម មានទំនាក់ទំនងការងារល្អ និងរួសរាយរាក់ទាក់
៥-មានឆន្ទៈក្នុងការបន្តរៀនសូត្រ ហាត់ធ្វើការ និងទទួលបទពិសោធន៍ថ្មីៗ
៦-មានភាពបត់បែនតាមតម្រូវការការងារទាំងក្នុង និងក្រៅអង្គភាព
៧-មានភាពអត់ធ្មត់ និងស្មារតីទទួលខុសត្រូវការងារខ្ពស់

- **កម្រិតអប់រំ៖**
  - សិស្ស និស្សិតដែលមានជំនាញពាក់ព័ន្ធកំពុងសិក្សាថ្នាក់ឧត្តមសិក្សា បញ្ចប់បរិញ្ញាបត្រ ឬ កម្រិតខ្ពស់ជាងនេះ
- **កាលបរិច្ឆេទទទួលពាក្យ៖**
  - ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ៥:០០ល្ងាច
  - ពាក្យស្នើសុំការងារអាចធ្វើការទាញយកពីគេហទំព័រ NEA (www.nea.gov.kh) និងទំព័រហ្វេសប៊ុក (National Employment Agency)
  - បញ្ជីឈ្មោះបេក្ខជនដែលត្រូវចូលសម្ភាសន៍នឹងត្រូវបានផ្តល់ដំណឹងតាមទូរស័ព្ទ ព្រមទាំងផ្សព្វផ្សាយតាមរយៈ៖
    - គេហទំព័រទីភ្នាក់ងារជាតិមុខរបរ និងការងារ: www.nea.gov.kh
    - **Facebook**: National Employment Agency

អាស្រ័យហេតុនេះ សិស្ស និស្សិត យុវជន និងសាធារណជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប និងពាក្យស្នើសុំការងារ មកទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាសយដ្ឋាន អាគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈអ៊ីម៉ែល **jc_pp@nea.gov.kh**។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទូរស័ព្ទលេខ៖ **016 786 655**។

ថ្ងៃ សុក្រ ៦ កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កុម្ភៈ ឆ្នាំ២០២០